ក្រងសម្ដីមាស

បណ្ដាំអ្នកប្រាជ្ញខ្មែរ

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

w.yerngshare.blogspot.c

បញ្ជីមាតិកា

បណ្ដាំក្រមង៉ុយ……………………………………………………………………១

ព្រះពុទ្ធ……………………………………………………………………៧

ព្រះរាជសម្ភារ……………………………………………………………………..១១

ព្រះបាទ អង្គឌួង……………………………………………………………………..២៤

សម្ដេចព្រះសង្ឃរាជ ជួន ណាត……………………………………………………………………២៦

ច្បាប់ល្បើកថ្មី……………………………………………………………………..២៧

ច្បាប់រាជនេតិ……………………………………………………………………២៩

ភិក្ខុឥន្ទបញ្ញោហ មណីចិន្ដា……………………………………………………………………៣០

ភាសិតបុរាណ……………………………………………………………………..៣៣

www.yerngshare.blogspot.com

www.elibraryofcambodia.org

បណ្តាំក្រមង៉ុយ

ឃើញឫកគេល្អ ទោះបីមានក្រ
យកគេជាញាតិ គួររាប់អ្នកក្រៅ
ជៅអ្នកឯទៀត រាប់រើសមារយាទ
សុចរិតត្រឹមត្រូវ។
រៀនបទរៀនបាទ កុំកោងហួសខ្នាត
កុំភ្លាត់ហួសផ្លូវ កុំភ្លើនភ្លេចម៉ែ
កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំសូវមើលងាយ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ

កុំប្រែក្រឡាស់ ក្រលេកឃើញគុណ

ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់

កុំគ្នះអ្នកក្រ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត

គ្រូសូត្រអក្សរ កុំចាប់ដៃទាញ

គំនាប់ឯក់ក កុំជជែកត

ស្មើមិត្តសំឡាញ់។

www.yerngshare.blogspot.com

www.elibraryofcambodia.org

កុំអួតកុំអាង កុំដើរមើលរាង

មើលអង្គអាត្មា កុំដើរផ្ទះគេ

ហួសពេលវេលា កុំទៅធានា

ទ្រព្យគេទាំងឡាយ។

កាន់ឬកធខ្ពស់ ធខ្មើមពាក្យឈ្លោះ

ទើបបានជាគាប់ យកឆោតដាក់ខ្លួន

ច្រើនមានគេរាប់ បើខ្លួនឥតទ្រព្យ

កុំធ្លាប់ហ៊ានខ្ចី។

www.yerngshare.blogspot.com

www.elibraryofcambodia.org

កូនចៅប្រុសស្រី រកប្រពន្ធប្ដី
ឲរកស្រុកជិត បើរកស្រុកឆ្ងាយ
ឲម្ដាយពិនិត្យ ឲត្រឹមត្រូវពិត
ពូជពង្សាវតារ។

កូនអើញអ្នកចាំ កុំជឿខែឆ្នាំ
កុំជឿតម្រា ពាក្យក្បួនតម្រាយ
កើតពីមនុស្សចារ ពីដូនពីតា
ចារតាមសម្គាល់។

www.yerngshare.blogspot.com

www.elibraryofcambodia.org

កូនចៅស្រីៗ ក្រមុំសាវខ្ចី

រៀនឆោតល្ងង់ ប្រុសស្មើម៉ែឪ

ឆ្លងឆប្រលោម មើលរូបមើលឆោម

កុំព្រមដោយងាយ។

កុំក្តិចក្តក់ក្តាញ់ បើចិត្តស្រឡាញ់

កុំចេញនិយាយ បើស្អប់កុំប្តឹង

បើខឹងកុំផ្លាយ កុំរួសកុំរាយ

កុំងាយធ្វើស្និទ្ធ។

កុំដើរប្រាប់គេ កុំអាងអួតជេរ

ក្រែងប្រុសចិត្តឈឺ នៅចតែនឹង

កុំរវល់ធ្វើស្និទ្ធ ប្រុសនឹងអាណិត

គិតចូលដណ្តឹង។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ម្តាយឪពុកនិងកូន បីដូចខ្លួននិងស្រមោល
ឃើញខុសកុំដេញដោល កុំផ្តោលទោសអ្នកមានគុណ។
លូង់ខ្លៅត្រូវតែសួរ ពាក្យធគួរកុំធស៊ិន
យកពាក្យផ្អែមជាមុន ទន់លំទោនឱនប្រណិប័តន៍។
ទោះម៉ែឪស្លូតកាច គួរតែខ្លាចដូចមហាក្សត្រ
ម្តាយជេរពីរបីម៉ាត់ គួរតែស្ងាត់ស្ងៀមធឈឹង។

ល្អមិនក្រយូរ ស្វែងរៀនរកគ្រូ
ស្ទូកុំស្តាយទ្រព្យ គ្រូវាយកុំខឹង
ធប្រឹងខំផ្ចាប់ ចេះមន្តសាយសព្វ
ត្រលប់ជាមាន។

www.yerngshare.blogspot.com
www.elibraryofcambodia.org

ព្រះពុទ្ធ

សេចក្ដីមិនប្រមាទ គឺជាផ្លូវនៃសេចក្ដីមិនស្លាប់

សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់។

បុគ្គលគួរតំកល់ខ្លួនឯងឲតាំងនៅក្នុងគុណធម៌ដ៏សមគួរជាមុនសិន ចាំប្រដៅអ្នកដទៃជាក្រោយទើបមិនលំបាក។

បុគ្គលណាធ្វេសប្រហែសក្នុងកាលមុន ដល់កាលជាខាងក្រោយមក បុគ្គលនោះមិនធ្វេសប្រហែសវិញ អ្នកនោះឯងឈ្មោះថា ញុំាងលោកនេះ ឲភ្លឺច្បាស់ដូចព្រះចន្ទផុតស្រឡះចាកពពក។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ឈ្មោះថាទីស្ងាត់របស់អ្នកធ្វើនូវបាបកម្មមិនមានក្នុងលោក ជនពាលរមែងសម្គាល់ស្ថានទីជាព្រៃដែលគេឃើញនោះ ថាជាទីស្ងាត់។

យសរមែងចម្រើនដល់អ្នកមានព្យាយាមរៀសរវៃ១ មានស្មារតី១ មានការងារស្អាត១ ពិចារណាហើយទើបធ្វើ១ ប្រុងប្រយ័ត្ន១ រស់នៅដោយធម៌១ ជាអ្នកមិនប្រមាទ១។

អ្នកឈ្នះគេរមែងប្រសព្វពៀរ អ្នកចាញ់គេរមែងនៅជាទុក្ខ បុគ្គលលះនូវការឈ្នះ និងការចាញ់ហើយស្ងប់រម្ងាប់ តែងនៅជាសុខ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

អវិជ្ជា គឺជាប្រភពនៃសេចក្ដីទុក្ខទាំងអស់។

បុគ្គលមិនមែនជាអ្នកថោកទាបព្រោះជាតិទេ មិនមែនជាអ្នកប្រសើរ ព្រោះជាតិទេ ជាអ្នកថោកទាបព្រោះកម្ម ជាអ្នកប្រសើរ ក៏ព្រោះកម្ម។

អ្នកណាមិនក្រោធ មិនតក់ស្លុត មិនអួតអាង មិនរង្កៀស ប្រសប់និយាយ មិនរាយមាយ អ្នកនោះឈ្មោះថា មុនី មានវាចាសង្រួមហើយ។

ការស្រេកឃ្លានជារោគដ៏កាចខ្លាំងបំផុត។

www.yerngshare.blogspot.com

www.elibraryofcambodia.org

បុគ្គលណាដឹងខ្លួន ឬសម្គាល់ខ្លួនថាជាមនុស្សល្ងង់ បុគ្គលនោះនឹងបានក្លាយទៅជាបណ្ឌិត ព្រោះការដឹងខ្លួននោះ។ បុគ្គលដែលជាអ្នកល្ងង់ខ្លៅ ហើយសម្គាល់ខ្លួនថាជាបណ្ឌិតនោះ តថាគតកំណត់ហៅថា ជាអ្នកល្ងង់ខ្លៅ។

ការក្រីក្រ គឺជាសេចក្តីទុក្ខរបស់លោក(សង្គម មនុស្ស)

ការជំពាក់បំណុលគេ គឺជាសេចក្តីទុក្ខរបស់លោក។

ការមិនមានរោគ គឺជាលាភដ៏ឧត្តមបំផុត។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជសម្ភារ

មនុស្ស៨ជំពូក ដែលព្រះរាជា ត្រូវលះបង់ចោល

១ មនុស្សខ្ជិលច្រអូស

២ មនុស្សមានចិត្តអាក្រក់

៣ មនុស្សល្ងង់ខ្លៅ

៤ មនុស្សមានមារយាទអាក្រក់

៥ មនុស្សធ្វើការរមែងខូច

៦ មនុស្សបិទបាំងទោសខ្លួន

៧ មនុស្សមិនសណ្ដោសគេ

៨ មនុស្សមិនក្លៀវក្លា

www.yerngshare.blogspot.com

www.elibraryofcambodia.org

មនុស្ស៧ជំពូកដែលព្រះរាជាមិនគួរធ្វើជាអ្នកសម្រេចការឡើយ

១ មនុស្សសម្ដីអាក្រក់

២ មនុស្សកាច់គេ

៣ មនុស្សលោភ

៤ មនុស្សមិនហាត់ក្នុងធម្មសាស្ត្រ

៥ មនុស្សឃើញតែប្រយោជន៍ខ្លួន

៦ មនុស្សមើលគុណម្ចាស់

៧ មនុស្សនិយាយកុហក

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជាគួរតម្កល់មនុស្ស ជាធំក្នុងទីពិភាក្សាផ្សេងៗ

១ មនុស្សមានត្រកូល

២ មនុស្សមានសីលគុណ

៣ មនុស្សមានពាក្យសត្យ

៤ មនុស្សមិនប្រព្រឹត្តក្នុងអគតិទាំង៤

៥ មនុស្សមានប្រាជ្ញា

៦ មនុស្សមានពាក្យពីរោះ

៧ មនុស្សឆ្លៀវឆ្លាតក្នុងរាជសាស្ត្រ និងធម្មសាស្ត្រ

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជាគួរតាំងមនុស្សប្រកបដោយគុណ៥ជាចៅហ្វាយឃ្លាំង

១ មនុស្សមានត្រកូលជាអ្នកទៀងត្រង់

២ មនុស្សព្យាយាមរក្សាទ្រព្យអោយល្អ

៣ មនុស្សស្គាល់ត្រកូលកែវទាំងពួង

៤ មនុស្សធ្វើការស្អាតមិនភ្លាំងភ្លាត់

៥ មនុស្សមានចិត្តទៀងត្រង់

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជាតាំងនាយទ្វារគួររើសមនុស្ស៦ជំពូក

១ អ្នកស្គាល់មនុស្សចាស់ថ្មី

២ មនុស្សមានស្មារតី

៣ មនុស្សមានរូបកាយសមរម្យ

៤ មនុស្សអត់ធន់នូវការលំបាក

៥ មនុស្សមានការងារល្អ

៦ មនុស្សឈ្លាសក្នុងការសាកសួរដំណ្លិត

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជាតាំងរាជទូតគួររើសមនុស្សប្រកបដោយគុណ៦យ៉ាង

១ មនុស្សមានប្រាជ្ញា

២ មនុស្សចេះដឹង

៣ មនុស្សក្លៀវក្លា

៤ មនុស្សចេះកំណត់ចិត្តអ្នកដទៃ

៥ មនុស្សមានគំនិតល្អិត

៦ មនុស្សដឹងពាក្យដែលគួរស្តី

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជាតាំងសេនាបតី គួររើសមនុស្សប្រកបដោយអង្គ៩

១ មនុស្សមានប្រាជ្ញា

២ មនុស្សដឹងទីជ័យភូមិ

៣ មនុស្សមិនចោលគ្នា

៤ មនុស្សដឹងកងពល ៣ហានៈលំបាក

៥ មនុស្សប្រកបដោយព្យាយាម

៦ មនុស្សក្លៀវក្លា

៧ មនុស្សអត់ធន់

៨ មនុស្សសុខទុក្ខនឹងពួកខ្លួន

៩ មនុស្សមានចំណេះ

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជានឹងតាំងរើសមនុស្សសេវកាប្រកបដោយគុណ៧

១ មនុស្សដឹងអធ្យាស្រ័យម្ចាស់

២ មនុស្សស្អាត

៣ មនុស្សឈ្លាសវៃ

៤ មនុស្សប្រព្រឹត្តធម៌

៥ មនុស្សចេះគម្ពីរជាច្រើន

៦ មនុស្សលោភតិច

៧ មនុស្សមិនភ្លេចស្មារតី

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជានឹងតាំងក្រុមវាំងត្រូវរើសមនុស្សប្រកបដោយអង្គ៧

១មនុស្សចេះរក្សាខ្លួន

២មនុស្សស្លូតត្រង់

៣មនុស្សឈ្លាសភាសា

៤មនុស្សត្រេកអរក្នុងធម៌

៥មនុស្សចេះសិល្បសាស្ត្រ

៦មនុស្សប្រកបដោយត្រកូល

៧មនុស្សកោតខ្លាចម្ចាស់

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជានឹងតាំងមន្ត្រីត្រូវរើសមនុស្សប្រកបដោយអង្គ៤

១ មនុស្សមានវិចារណបញ្ញា

២ មនុស្សម្ចាស់មានវល់មិនធុញទ្រាន់

៣ មនុស្សក្លៀវក្លា

៤ មនុស្សមានសេចក្ដីគិតអានច្រើន

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះរាជាប្រសើរប្រកបដោយអង្គ៦

១ មានសម្ព័ន្ធមិត្តអាចញាំញីបរបក្ស ហើយវាងវៃក្នុងការណរង្គ កាច់បង់នូវកលនៃបរបក្ស ហើយជាទីពឹងនៃប្រជាជន

២ ទ្រង់រំលឹកនូវការងារទាំងពួង

៣ ចេះធ្វើបរបក្សឲបាក់បបដោយយុត្តិធម៌

៤ មានព្រះហឫទ័យក្លៀវក្លា និងព្យាយាមច្រើន

៥ មានស្មារតីខ្ជាប់ខ្ជួន

៦ ទ្រង់ព្រះប្រាជ្ញាជ្រាបការវិនាស និងចម្រើន

www.yerngshare.blogspot.com

www.elibraryofcambodia.org

អ្នកប្រកបដោយអង្គ៨ទើបធ្វើមន្ត្រីបាន

១ បានស្ដាប់មកច្រើន

២ មានសីលគុណ

៣ មានព្យាយាមច្រើន

៤ ធ្វើរាជការរួចឆាប់

៥ មានកម្លាំងច្រើន

៦ លោភតិច

៧ មានរូបជាទីស្រលាញ់

៨ ក្លៀវក្លា

www.yerngshare.blogspot.com

www.elibraryofcambodia.org

ខ្លែងហើរត្បិតខ្យល់	នាយថ្កើងដ្បិតពល
រក្សាធសុខ	ទ្រព្យគង់ដ្បិតស្រី
ចេះសំចៃទុក	ផ្ទះធំស្រណុក

ដ្បិតភរិយាជា។

ចង់បុណ្យបានបាប	ចចើងចង់លាភ
វែងបាត់ធនទៅ	មានះបាត់មិត្ត
ឥតអ្នកជាជៅ	ក្រេវក្រោធឃោរឃៅ

រមែងបាត់អង្គ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ព្រះឱវាទ អង្គឌួង

អស់ប្រុសទាំងឡាយ ចូរចាំអធិប្បាយ
ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសប្រាណ
កុំមានកន្ដើយ មានប្រពន្ធហើយ
ជាសុខសម្រាន្ត។

មួយគឺចប្ដី ហៅប្រើស្រដី
នឹងប្រពន្ធមាន ពាក្យទន់ពីរោះ
ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន
តាមសព្វវាចារ។

មួយគឺប្រពន្ធ ខុសឆ្គងស្រាលធ្ងន់
កុំជេរផ្ដាសា ទាត់ធាក់ដៀលដំ
ដូចខ្ញុំអាត្មា កុំស្ដីដើមថា
ចលីសាយសព្វ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

មួយគឺបានធន ប្រគល់ប្រពន្ធ
ទុកដាក់រណ្ដាប់ ទាំងគ្រឿងអាហារ
ជាការស្រីផ្ដាប់ រៀបចំសម្រាប់
ថៃទាំរក្សា។

មួយគឺកុំផ្ទង់ កុំខំតែបង់
កើតកូនហើយថា ប្រពន្ធសុខចិត្ត
ឲគិតប្រាថ្នា រួសរកទ្រព្យា
សម្រាប់ឲផង។

មួយគឺឲចាប់ ស្រឡាញ់ឲខ្ជាប់
កុំជិនណាយហោង បើមានប្រពន្ធ
ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង
ឲស្មើមិនឡើយ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

សម្តេចព្រះសង្ឃរាជ ជួន ណាត

កើតមកជាកូនប្រុសត្រូវតែខំប្រឹងបំពេញករណីយកិច្ច

លុះត្រាតែបានសម្រេច។

ការអ្វីមិនទាន់ស្រេច កុំអាលប្រញាប់ពោលអួត។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ច្បាប់ល្បើកថ្មី

ម៉ែឪមានគុណ គុណមានទម្ងន់

ធ្ងន់ដូចប្រឹថពី គ្មានអ្វីនឹងសង

គុណលោកទាំងទ្វី មាសប៉ុនគិរី

ថ្លៃពុំស្មើហោង។

រីគ្រូបាធ្យាយ គួរទុកដូចម្ដាយ

ឪពុកយើងផង ប្រិតប្រៀនប្រដៅ

ដោយនៅគន្លង ពុំធ្លោំធ្លង

នឹងច្បាប់សាលា។

www.yerngshare.blogspot.com

www.elibraryofcambodia.org

កុំឆ្មើងអាងបុណ្យ ស្រដីធទន់
ពោលពាក្យពីរោះ ខ្លួនអ្នកនឹងថ្កើង
នឹងឡើងសក្តិយស កុំឆ្លៀតនាំឈ្លោះ
ញុះញង់អ្នកធំ។

កុំស្អប់អ្នកតូច បើមើលគ្នាខូច
គួរគិតប្រមិម ទោសគ្នាតិចតួច
ផ្តួចឡើងជាធំ ជ្រែងពួតជាជុំ
ផ្តុំឆេះជាភ្លើង។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ច្បាប់រាជនេត

ទាហានថ្លើងដ្បិតសឹក ធ្វើស្រែដ្បិតទឹក

ត្រីកពលព្រោះបាយ សិស្សប្រាជ្ញដ្បិតគ្រូ

ដេរពោលដំវាយ ពលថ្លើងត្បិតនាយ

ហ្វឹកហ្វឺនខះខំ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

គុណធម៌របស់ មេដឹកនាំ

លក្ខណៈរបស់មេតាមទ្រឹស្ដីព្រះពុទ្ធសាសនាទាំង១០យ៉ាង

១ ថេរោ រតញ្ញូ អ្នកដឹកនាំគួរជាមនុស្សដែលមានវ័យច្រើន មានការពិសោធន៍ក្នុងកិច្ចការយូរ។

២ សីលវា គោរពតាមច្បាប់ តាមវិន័យ មិនព្រមប្រព្រឹត្តល្មើសច្បាប់ ជាអ្នកមានកាយវាចារល្អប្រពៃ មិនមានស្លាកស្នាម ខាងអំពើទុច្ចរិត។

៣ ពហុស្សុតោ ជាអ្នកចេះច្រើន មានចំណេះវិជ្ជាខ្ពស់

៤ ស្វាគតបាដិមោក្ខោ ដឹងគោលច្បាប់ គោលវិន័យ ច្បាប់ជាតិ និងអន្តរជាតិ។

៥ អធិករណសមុប្បាទវូបសមកុសលោ ជាអ្នកវៃឆ្លាតពូកែក្នុងការរំងាប់ការទាស់ទែងក្នុងសង្គម។

៦ ធម្មកាមោ ចូលចិត្តគោរពច្បាប់ គោរពធម៌ យកធម៌ជាធំ ស្រឡាញ់ការចេះដឹង។

៧ សន្តុដ្ឋោ មិនលោភលន់ មិនខ្ជះខ្ជាយ

៨ ឈានលាភី មានសុខភាពចិត្តល្អបរិបូរណ៍ មិនងាយខឹង

៩ បាសាទិកា មានកិរិយាមារយាទគួរអោយជ្រះថ្លា

១០ អនាសវចេតោវិមុត្តិបញ្ញាវិមុត្តិ ចេះគ្រប់គ្រងខ្លួន មិនជាប់ជំពាក់នឹងសរសើរ និន្ទាបានលាភ អត់លាភបានយសសក្តិបានសុខ និងទុក្ខ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

១ សុតៈ ការរៀនឬស្តាប់ចេះចាំទាំងផ្លូវលោកផ្លូវធម៌ ខាងផ្លូវលោក គឺការចេះដឹងនូវវិជ្ជាទាំង៥ប្រការគឺៈ ១ នីតិវិជ្ជា ការចេះដឹងខាងផ្លូវច្បាប់សម្រាប់លោកសម្រាប់សាសនា ស្គាល់កិច្ចកលឧបាយគ្រប់យ៉ាងតាំងពីអក្សរសាស្ត្រជាដើមឡើង។

២ រដ្ឋវិជ្ជា ការចេះដឹងច្បាប់រដ្ឋបាលសម្រាប់គ្រប់គ្រងប្រទេស ស្គាល់ផ្លូវរដ្ឋប្រសាសនោបាយក្នុងប្រទេសរបស់ខ្លួនឬប្រទេសដទៃ ដើម្បីនឹងប្រាស្រ័យចរចាទៅនានាជាតិបានដោយស្រួល។

៣ វេជ្ជវិជ្ជា ការចេះដឹងក្នុងវេជ្ជសាស្ត្រ ស្គាល់សមុដ្ឋានដែលបណ្តាលឲកើតរោគ ចេះដឹងក្នុងវិធីផ្សំថ្នាំសម្រាប់ម្ងាប់មេរោគ។

៤ យន្តវិជ្ជា ចេះដឹងក្នុងផ្លូវការរបស់ជាង ដែលអាចធ្វើគ្រឿងចក្រយន្តយានតាមកាលសម័យដែលលោកនិយម។

៥ យុទ្ធវិជ្ជា ការចេះដឹងក្នុងផ្លូវយុទ្ធសាស្ត្រ សម្រាប់ការពារប្រទេសជាតិ។

វិជ្ជាទាំង៥ប្រការនេះ ជាវិជ្ជាខាងផ្លូវលោក។

ឯវិជ្ជាខាងផ្លូវធម៌នោះគឺ ការចេះដឹងក្នុងផ្លូវព្រះពុទ្ធសាសនា ចាំស្ទាត់ចូលចិត្តពិតប្រាកដមិនភាន់ច្រឡំ ដូចជាចេះព្រះត្រៃបិដក ចេះប្រែសេចក្តីត្រឹមត្រូវតាមរបៀបវេយ្យាករណ៍ មានស្គាល់ប្រយោគ អានាទរលក្ខណៈ ឥត្ថម្ភូតៈជាដើម។

សេចក្តីចេះដឹងក្នុងវិជ្ជាការ តម្រាក្បួនច្បាប់ផ្លូវលោកផ្លូវធម៌ប៉ុណ្ណោះជាដើម ចាត់ចូលក្នុងសុតៈទាំងអស់ ព្រោះហេតុថាការចេះដឹងដែលកើតមកអំពីការរៀនការស្តាប់។ សុតៈដូចបានពោលមកនេះទើបចាត់ថាជាទ្រព្យដ៏ប្រសើរ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

៦ ចាគៈ ការបរិច្ចាគលះបង់ទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីសាងសាធារណៈប្រយោជន៍មានវិហារ កុដិ សាលា មន្ទីរពេទ្យ ជីកស្រះ លើកថ្នល់ សង់ស្ពាន ឲប្រទីបចង្កៀងគោម ឲប្រដាប់សម្រាប់សិក្សារៀនសូត្រដល់ជនទូទៅ ទើបចាត់ជាទ្រព្យដ៏ប្រសើរ។

៧ បញ្ញា គឺធម្មជាតិម្យ៉ាងដែលមានសេចក្ដីឈ្លាសវៃ ស្គាល់ហេតុស្គាល់ផល បាបបុណ្យគុណទោស ស្គាល់ហេតុនាំឲចំរើននិងវិនាសទាំងបច្ចុប្បន្នទាំងអនាគត ចេះរក្សាខ្លួនបានដោយសុខស្រួលនៅក្នុងលោកចាត់ជាលោកិយប្បញ្ញា បញ្ញាដែលឆ្លងចាកលោក បានដល់មគ្គផលនិព្វានចាត់ជាលោកុត្តរប្បញ្ញា។ ផ្លូវដែលនាំឲកើតបញ្ញាមាន៣យ៉ាងគឺៈ ការស្ដាប់ហៅថាសុតៈ១ ការគិតហៅថាចិន្តៈ១ ការអប់រំហៅថាភាវនា១។

បញ្ញាដែលបានពោលមកប៉ុណ្ណេះ ទើបចាត់ជាទ្រព្យដ៏ប្រសើរ។

ធម៌ទាំង៧ប្រការមានសទ្ធាជាដើម បានជាលោកឲឈ្មោះថាអរិយទ្រព្យនោះព្រោះជារបស់បិតបេរខ្ជាប់ខ្លួន មិនចេះវិនាសសាប

សូន្យដោយប្រការផ្សេងៗឡើយ ចំពោះអគ្គិភ័យក៏មិនអាចឆាបឆេះបាន ទោះបីអំពើចោរកម្ម ក៏មិនងាយនឹងឆក់ដណ្ដើមកើត។

បុរសស្ត្រីណា មានអរិយទ្រព្យ៧ប្រការនេះ លោកអ្នកប្រាជ្ញ មានព្រះសម្មាសម្ពុទ្ធជាដើម ពោលថាការរស់នៅនៃជនទាំងនោះឈ្មោះថាការរស់នៅប្រកបដោយប្រយោជន៍ មិនមែនជាជីវិតរស់នៅឥតអំពើឡើយ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

ភាសិតបុរាណ

នារីរូបខ្មៅអាក្រក់ក្រៃ

តែមារយាទថ្លៃចិត្តសោភា

វិសេសជាងស្រីល្អរូបា

ចិត្តលោភាមិនល្មមនឹងកាមរោគ។

នៅមូលបងប្អូនកូនប្រពន្ធ

ថ្នមចិត្តទន់ធ្ងន់កុំអាលជេរ

បើឃើញខ្លះខ្ជិលនៅទំនេរ

កុំស្មៀមទទេដាស់តឿនទៅ។

www.yerngshare.blogspot.com

www.elibraryofcambodia.org

www.yerngshare.blogspot.com

www.elibraryofcambodia.org